ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ០២ ប្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០

នៅព្រឹកថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។**

**២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។**

**៣-គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តឧត្តរមានជ័យមកអនុស្ថានីយខាងកើតសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្មនាំចូល៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងការអនុវត្តបន្តទៀត។**

**៤-បញ្ហាផ្សេងៗ៖**

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ៖

៤.១.សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៤.២.សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៤.៣.ពិធីសារទីមួយ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន។

៤.៤.ពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

៤.៥.ពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេច៖

## ១-អនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ស្របពេលដែលពិភពលោកបានដើរមកដល់របត់នៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ដែលកំពុងមានការអភិវឌ្ឍយ៉ាងលឿនរហ័ស ដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាសកល កម្ពុជាត្រូវការជាចាំបាច់នូវយន្តការគ្រប់គ្រងមួយច្បាស់លាស់លើរបត់ថ្មីនេះ ដើម្បីធ្វើយ៉ាងណាធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនប្រកបដោយចីរភាពនិងមានភាពប្រកួតប្រជែងខ្ពស់ សំដៅធ្វើឱ្យកម្ពុជាសម្រេចបានចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ក្នុងន័យនេះ តាមការសម្រេចរបស់រាជរដ្ឋាភិបាល និងតាមចក្ខុវិស័យដ៏ទូលំទូលាយនិងយូរអង្វែងរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវបានអនុញ្ញាតជាគោលការណ៍ឱ្យប្តូរឈ្មោះទៅជា ក្រសួងឧស្សាហកម្ម **វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជាស្របទៅតាមបរិបទនៃបច្ចេកវិទ្យា វិទ្យាសាស្ត្រ ក៏ដូចជានវានុវត្តន៍(របកគំហើញថ្មី) ដែលកំពុងវិវត្តទៅយ៉ាងឆាប់រហ័ស មានលក្ខណៈជាសកល និងដើម្បីធ្វើឱ្យការស្រាវជ្រាវលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(របកគំហើញថ្មី)ផ្សេងៗរបស់កម្ពុជា ទទួលបានប្រសិទ្ធភាព និងពង្រីកសក្តានុពលទូលំទូលាយក្នុងយុគសម័យបច្ចុប្បន្ននិងទៅអនាគត ព្រមទាំងជំរុញនិងទាក់ទាញវិទ្យាសាស្ត្រឱ្យមានការរីកចម្រើន និងជំរុញការផ្ទេរបច្ចេកវិទ្យា ស្របតាមបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០។

តាមរយៈការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងធ្វើឱ្យកម្ពុជាមានស្ថាប័នមួយទទួលបន្ទុកច្បាស់លាស់ជាក់លាក់ជាលើកដំបូងនៃប្រវត្តិសាស្ត្ររបស់ខ្លួន ក្នុងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការលើកទឹកចិត្តចំពោះនវានុវត្តន៍(របកគំហើញថ្មី) ដែលជាជំហាននៃកំណែទម្រង់មួយកម្រិតទៀត ធ្វើឱ្យវិស័យនេះផ្សារភ្ជាប់ទៅនឹងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ក៏ដូចជាពិភពលោក។

សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានដាក់ប្រជុំក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០។

សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលបានអនុម័តនេះមាន៨មាត្រា នឹងត្រូវដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត។

## ២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានដាក់ប្រជុំក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចប្រគល់ភារកិច្ចជូន ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យនិងកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យនេះ ដោយផ្អែកលើទស្សនទាននិងធាតុចូលស្របតាមស្មារតីនៃការពិភាក្សារបស់អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាពេលនេះ។

**៣-អនុម័តគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តឧត្តរមានជ័យមកអនុស្ថានីយខាងកើតសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្មនាំចូល៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងការអនុវត្តបន្តទៀត**

ស្របតាមផែនការមេអភិវឌ្ឍប្រភពអគ្គិសនីបន្ថែមពីឆ្នាំ២០២០ដល់ឆ្នាំ២០៣០ រាជរដ្ឋាភិបាលបានសម្រេចអនុម័តគម្រោងវិស័យអគ្គិសនីចំនួន៣បន្ថែមទៀត ដែលរួមមាន៖ ទី១)-គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទី២)-គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តឧត្តរមានជ័យមកអនុស្ថានីយខាងកើតសៀមរាប និង ទី៣)-គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្មនាំចូល៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង។

ដោយគម្រោងវិនិយោគទាំង៣នេះ មានភាពចាំបាច់ក្នុងការបំពេញឱ្យបានគ្រប់គ្រាន់នូវប្រភពអគ្គិសនីធានាសុវត្ថិភាពនិងសន្តិសុខនៃការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ធានាឱ្យមានស្ថិរភាពផ្គត់ផ្គង់នៅរដូវប្រាំងដែលវារីអគ្គិសនីរបស់យើងមួយភាគធំពុំមានលទ្ធភាពផលិតបានច្រើន ការចរចាលើបច្ចេកទេសនិងហិរញ្ញវត្ថុមានលក្ខណៈសមរម្យ អាចចូលរួមបន្ថយថ្លៃអគ្គិសនីបន្ថែមទៀតជូនអ្នកប្រើប្រាស់អគ្គិសនីនៅកម្ពុជា ឆ្លើយតបនឹងគោលនយោបាយបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល និងម្យ៉ាងទៀតកង្វល់លើបញ្ហាបរិស្ថានត្រូវបានដោះស្រាយសមស្របតាមគោលការណ៍របស់ក្រសួងបរិស្ថានរួចហើយ រាជរដ្ឋាភិបាល បានសម្រេចដូចខាងក្រោម៖

១-អនុម័តឱ្យក្រុមហ៊ុន HAN SENG COAL MINES CO.,LTD. (HSCMC) ធ្វើការវិនិយោគលើគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដោយប្រើរ៉ែធ្យូងថ្មដែលជីកបាននៅតំបន់នោះ និងធ្វើការវិនិយោគលើគម្រោងអភិវឌ្ឍបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ភ្ជាប់ពីរោងចក្រអគ្គិសនីដុតធ្យូងថ្មរបស់ក្រុមហ៊ុនមកអនុស្ថានីយខាងកើតសៀមរាប។

២-អនុម័តឱ្យក្រុមហ៊ុន ROYAL GROUP ធ្វើការវិនិយោគលើគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្មនាំចូល៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង។

៣-អនុញ្ញាតឱ្យក្រសួងរ៉ែនិងថាមពល ចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយក្រុមហ៊ុនទាំង២ខាងលើ តាមគម្រោងដែលក្រុមហ៊ុនត្រូវធ្វើការវិនិយោគនីមួយៗ។

៤-អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះហត្ថលេខាលើលិខិតធានារបស់រាជរដ្ឋាភិបាលសម្រាប់គម្រោងដែលក្រុមហ៊ុនត្រូវធ្វើការវិនិយោគនីមួយៗ។

៥-អនុញ្ញាតឱ្យអគ្គិសនីកម្ពុជា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីជាមួយក្រុមហ៊ុនទាំង២ខាងលើ តាមគម្រោងដែលក្រុមហ៊ុនត្រូវធ្វើការវិនិយោគនីមួយៗ។

៦-ធ្វើសំណើសុំទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីអនុម័តយល់ព្រមលើលិខិតធានារបស់រាជរដ្ឋាភិបាលសម្រាប់គម្រោងដែលក្រុមហ៊ុនត្រូវធ្វើការវិនិយោគនីមួយៗ។

គម្រោងអភិវឌ្ឍទាំង៣ខាងលើ ត្រូវបានដាក់ប្រជុំក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០។

**៤-បញ្ហាផ្សេងៗ៖**

៤.១. កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចបញ្ជូនទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ៖

១. សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

២. សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៣. ពិធីសារទីមួយ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន។

៤. ពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

៥. ពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

៤.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការផ្សព្វផ្សាយអំពី៖

- ដំណើរទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅនេះ គឺជាការបង្ហាញនូវសាមគ្គីភាពជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិននិងប្រជាពលរដ្ឋចិននៅក្នុងគ្រាលំបាកនេះ ក៏ដូចជាពង្រឹងនូវស្មារតីនិងជំនឿចិត្តសម្រាប់ប្រជាពលរដ្ឋនិងនិស្សិតកម្ពុជាដែលរស់នៅនិងសិក្សានៅប្រទេសចិន ឱ្យបន្តស្នាក់នៅប្រទេសចិន និងរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋចិន។ សម្តេចតេជោ បានគូសបញ្ជាក់ថា កម្ពុជាគឺនៅកាន់តែជិតជាមួយមិត្តចិន ជាពិសេសក្នុងកាលៈទេសៈដ៏លំបាកនេះ ព្រោះថា "មិត្តល្អមិនបោះបង់ចោលគ្នាក្នុងគ្រាលំបាក"។

- ជំងឺរបស់ប្រជាពលរដ្ឋកម្ពុជាមិនមែនជាជំងឺរលាកសួតដោយវីរុសកូរ៉ូណាថ្មី (2019-nCoV) នោះទេ ក្នុងកាលៈទេសៈនេះគឺជា«ជំងឺភ័យខ្លាច»។

សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវឱ្យប្រជាពលរដ្ឋគ្រប់រូបរក្សាភាពនឹងនរ ពិសេសរក្សាអនាម័យក្នុងការរស់នៅ ការទទួលទាន និងការធ្វើការងារ ដើម្បីបញ្ចៀសបាននូវការឆ្លងមេរោគគ្រប់ប្រភេទ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង៣០នាទី។

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០